ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត បាត់ដំបង

អង្គភាព៖ អង្គការខ្មែរដើម្បីការអប់រំ ( KHEN )

# ការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ ២០១៨ ( ពីខែមករា ដល់ ធ្នូ ឆ្នាំ២០១៨ )

| ឈ្មោះសកម្មភាព ក្នុងផែនការ | ស្ថានភាព | លទ្ធផលសម្រេច ( ធាតុចេញ ) | លទ្ធផលរំពឹងទុក | ថវិកាបានអនុវត្ត | | សេចក្តីបញ្ជាក់ |
|---|---|---|---|---|---|---|
| | | | | រដ្ឋ | ដៃគូ | |
| **សរុបរួមទូទាំងខេត្តបាត់ដំបង** | | | | - | 1,362,768,700.00 | |
| **កម្មវិធីទី១៖ ការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ** | | | | | 107,832,700.00 | |
| **១.១ ការពង្រីកការអប់រំកុមារតូច** | | | | - | 40,234,900.00 | |
| សកម្មភាពគោលទី ១:ពង្រឹងការអភិវឌ្ឍសេវាអប់រំកុមារតូច និងពិនិត្យតាមដាន | | | បង្កើតនិងដំណើរការ គាំទ្រដល់ សាលាឧបសម្ព័ន្ធនិងសាលារដ្ឋតាមជនបទ (១៥សាលាក្នុងស្រុកសំឡូត និង ១៥សាលាក្នុងស្រុករុក្ខគិរី) | - | 40,234,900.00 | |
| ១.១ ពង្រីកថ្នាក់មត្តេយ្យសិក្សារដ្ឋ | 1 | ខេនបានសហការពង្រីកថ្នាក់មត្តេយ្យសិក្សារដ្ឋបានចំនួន ២ថ្នាក់នៅក្នុងសាលាសហគមន៍ដូនត្រិត និងឆ្អោងក្រៅ នៃស្រុកសំឡូត | សហការគាំទ្រ (តាមការចាំបាច់) | | 28,000.00 | |
| ១.២ ពង្រីកថ្នាក់មត្តេយ្យសិក្សាសហគមន៍ | 1 | គាំទ្រដំណើរការថ្នាក់រៀន និងកិច្ចសន្យាគ្រូមត្តេយ្យ សហគមន៍បានចំនួន ៩ សាលារៀននៅក្នុងស្រុកសំឡូត នឹង ៨សាលានៅក្នុងស្រុករុក្ខគិរី។ សិស្សសរុបចំនួន ១៤៥នាក់ (ស្រី ៦៨នាក់) បានចូលរៀននៅក្នុងសាលាគោលដៅទាំង ៩នៅក្នុងស្រុកសំឡូត និងសិស្សចំនួន ១៤៨នាក់ (ស្រី ៩១នាក់) បានចូលរៀននៅក្នុងសាលាគោលដៅទាំង ៨នៅក្នុងស្រុករុក្ខគិរី។ | គាំទ្រដំណើរការថ្នាក់រៀន និង កិច្ចសន្យាគ្រូសហគមន៍ (មត្តេយ្យសិក្សាសហគមន៍)ចំនួន ១១ សាលានៅស្រុកសំឡូត នឹង ៨សាលានៅស្រុករុក្ខគិរី | | 24,203,200.00 | ធ្វើការគាំទ្រប្រចាំខែ (១ឆ្នាំ ១០ខែ) |
| ១.៣ បំពាក់សម្ភារៈបរិក្ខា សម្ភារៈរៀននិងបង្រៀន សម្ភារៈល្បែងក្នុង និងក្រៅថ្នាក់ | 1 | សាលាសហគមន៍ចំនួន ៩ (ស្រុករុក្ខគិរី (បឹងអំពិល, អូរច្រកថ្លាង, បឹងចក, ធ្នួយ និងប៉ាលហាល), ស្រុកសំឡូត (កំពង់ត្រាំង, ឆ្អោងក្រៅ, ស្រែពន្លក និងអូរអន្សង)) បានបំពាក់សម្ភារៈបរិក្ខា សម្ភារៈរៀន និងបង្រៀនសម្រាប់ថ្នាក់មត្តេយ្យរួចរាល់ហើយ។ | ថ្នាក់មានសម្ភារៈបង្រៀននិងរៀនសម្រាប់សិស្សមត្តេយ្យ | | 7,237,800.00 | |

| | | | | | | |
|---|---|---|---|---|---|---|
| ១.៤ បំប៉នសមត្ថភាព/បណ្តុះបណ្តាលអ្នកគ្រប់គ្រង និង វិក្រឹតការបុគ្គលិកលើកិច្ចគាំពារ និងអភិវឌ្ឍកុមារតូច | 1 | គ្រូមត្តេយ្យសហគមន៍ចំនួន ៤០នាក់ (ស្រី ៤០នាក់) បានចូលរួមវគ្គបំប៉នសមត្ថភាពលើការរៀន និងបង្រៀន កិច្ចការងាររដ្ឋបាល ការផលិត សម្ភារៈ ការទស្សនៈកិច្ចសាលាមត្តេយ្យក្រុង នឹងកិច្ចការពារកុមារ បានចំនួន ៤ដងនៅក្នុងស្រុករុក្ខគិរីចំនួន ៣ដង និងស្រុកសំឡូតចំនួន ១ដង។ | ជ្រើសរើស និងគាំទ្របំប៉នគ្រូមត្តេយ្យ សហគមន៍ ដែលរួមបញ្ចូលទាំងការដាក់ពង្រាយគ្រូបង្រៀនទៅបង្រៀននៅសាលាឧបសម្ព័ន្ធ (ដែលរួមទាំងគ្រូកិច្ចសន្យា),(ស្រុកសំឡូត និង ស្រុករុក្ខគិរី)។ ធ្វើការបណ្តុះបណ្តាលទៅគ្រូមត្តេយ្យ (ស្រុកសំឡូត និង ស្រុករុក្ខគិរី)វគ្គបណ្តុះបណ្តាលចំនួន ៤ ត្រូវបានផ្តល់ជូនគ្រូបង្រៀនតាមសាលាមត្តេយ្យសិក្សាសហគមន៍ ។ គ្រូបង្រៀនមត្តេយ្យសិក្សាចំនួន ២៥នាក់ បានទទួលការបណ្តុះបណ្តាល។ | | 7,466,600.00 | |
| ១.៥ ការចុះពិនិត្យតាមដានការងាររៀន និងបង្រៀន និង ការគាំពារ<br>និងអភិវឌ្ឍកុមារតូច | 1 | ក្រុមបំប៉នពិនិត្យតាមដាន និងវាយតម្លៃថ្នាក់ស្រុក បានចុះទៅពិនិត្យការងាររៀន និងបង្រៀន ការគាំពារនិងការអភិវឌ្ឍកុមារតូចបានចំនួន ១៨សាលារៀនគោលក្នុង (១៥សាលាគោលដៅនៅស្រុករុក្ខគិរី និង ៣សាលាគោលដៅនៅក្នុងស្រុកសំឡូត) | ការចុះជាប្រចាំខែគាំទ្របច្ចេកទេស | | 1,299,300.00 | |
| **ឈ្មោះសកម្មភាព ក្នុងផែនការ** | **ស្ថានភាព** | **លទ្ធផលសម្រេច (ធាតុចេញ )** | **លទ្ធផលរំពឹងទុក** | **ថវិកាបានអនុវត្ត** | | **សេចក្តីបញ្ជាក់** |
| | | | | **រដ្ឋ** | **ដៃគូ** | |
| **១.២ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅបឋមសិក្សា** | | | | - | **54,300,100.00** | |
| សកម្មភាពគោលទី ១:ការពង្រឹងសមត្ថភាព លើកកម្ពស់បច្ចេកទេសបង្រៀន និងរៀន | | | សមត្ថភាពបំពេញការងារ និងបច្ចេកទេសបង្រៀនត្រូវបានលើកកម្ពស់ | - | 38,427,500.00 | |
| ១.១.ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនិងអភិវឌ្ឍធនធានទិន្នន័យ,និងទំរង់ដែលរួមទាំង ToR ដោយផ្តែកលើអប្បរមារស្តង់ដារសាលាកុមារមេត្រី (ស្រុកសំឡូត និង ស្រុករុក្ខគិរី) | 1 | ក្រុមការងារគម្រោង, ក្រុមបំប៉នពិនិត្យតាមដាន និងវាយតម្លៃថ្នាក់ស្រុក និងមន្ត្រីជំនាញអប់រំស្រុកបានចុះសិក្សា និងប្រមូលទិន្នន័យបឋមតាមសាលាគោលដៅចំនួន ២៨សាលាគោលដៅ (១៥សាលារៀនគោលដៅនៅក្នុងស្រុករុក្ខគិរី និង ១៣សាលានៅស្រុកសំឡូត) បានចំនួន ២ដង (នៅក្នុងស្រុករុក្ខគិរីចំនួន ១ដង និងស្រុកសំឡូតចំនួន ១ដង)។ | ចុះសិក្សានិងប្រមូលទិន្នន័យបឋមតាមសាលាគោលដៅ ស្តីពី ស្តង់ដាកុមារមេត្រី | | 3,824,600.00 | |

| | | | | | | |
|---|---|---|---|---|---|---|
| ១.២.ការផ្សព្វផ្សាយគម្រោង (ស្រុកសំឡូត និង ស្រុករុក្ខគិរី) | 1 | ការផ្សព្វផ្សាយគម្រោងទាំងក្នុងស្រុករុក្ខគិរី និងសំឡូតត្រូវបានបញ្ចប់ដោយមានអ្នកការសហការជាមួយអភិបាលនៃគណៈអភិបាលស្រុក, ការិយាល័យអប់រំស្រុក, គកសក, ក្រុមប្រឹក្សាស្រុក, គកនគ, មេឃុំ, ប៉ូលីស, គ្រូពេទ្យ, អាជ្ញាធរភូមិ/ឃុំ, នាគកម្រង, នាយកសាលា, គ្រូបង្រៀន,គណៈកម្មការទ្រទ្រង់សាលា,សហគមន៍ នឹងអង្គការដៃគូរ។ អ្នកចូលរួមសរុបមានចំនួន ១៨៩នាក់ (ស្រី ៤៦នាក់) ក្នុងនោះមានជនពិការចំនួន ១នាក់។ | រៀបចំនិងស្វែករកិច្ចសហប្រតិបត្តិការងារជាមួយគម្រោង | | 6,023,100.00 | |
| ១.៣. គាំទ្រកិច្ចពិគ្រោះយោបល់ និងបង្កើតផែនការសកម្មភាពជាមួយសាលារៀន និងឃុំ (ស្រុកសំឡូត និង ស្រុករុក្ខគិរី) | 1 | ការប្រជុំចំនួន ២៨ដងបានធ្វើឡើងនៅក្នុងសាលាគោលដៅចំនួន ២៨សាលា ដោយមានការចូលរួមពី នាយកសាលា, គណៈកម្មការ, គ្រូបង្រៀន និងអាជ្ញាធរភូមិឃុំ។ ផែនការក្នុងការធ្វើយុទ្ធនាការចំនួន ២៨បានរៀបចំឡើងជាមួយអ្នកចូលរួមទាំងអស់គ្នា។ | មានផែនការក្នុងការធ្វើយុទ្ធនាការចុះឈ្មោះចូលរៀន | | 354,700.00 | សកម្មភាពនេះកើតឡើងប្រចាំឆ្នាំ |
| ១.៤. គាំទ្រការធ្វើយុទ្ធនាការចុះឈ្មោះ នឹងប្រមូលកុមារចូលរៀននៅក្នុងខែ តុលា ចាប់ពីថ្ងៃទី ១៥-៣០(ស្រុកសំឡូត និង ស្រុករុក្ខគិរី) | 1 | ក្រុមកការងារគម្រោងបានធ្វើយុទ្ធនាការប្រមូលសិស្សចូលរៀនបានចំនួន ២៨សាលារៀន/ ភូមិ/ ចំនុច (១៥សាលារៀននៅក្នុងស្រុករុក្ខគិរី និង ១៣ សាលារៀននៅក្នុងសំឡូត) ដែលមានអ្នកចូលរួមសរុបចំនួន ២៦៧នាក់ (ស្រី ១១២នាក់) (រុក្ខគិរីចំនួន ១២៨នាក់ (ស្រី ៤៣នាក់) និងសំឡូតចំនួន ១៣៩ នាក់ (ស្រី ៦៩នាក់))។<br><br>បន្ទាប់ពីធ្វើយុទ្ធនាការប្រមូលសិស្សចូលរៀនមក, កុមារថ្មីចំនួន 770នាក់ អាយុពី ៣-៦ឆ្នាំបានមកចុះឈ្មោះចូលរៀននៅក្នុងសាលារៀនគោលដៅចំនួន ២៨ (៣៩៩ នាក់បានចុះឈ្មោះចូលរៀននៅក្នុងសាលារៀនចំនួន ១៥នៅក្នុងស្រុករុក្ខគិរី និង ៣៧១នាក់បានចុះឈ្មោះចូលរៀននៅក្នុងសាលារៀនគោលដៅចំនួន ១៣នៅក្នុងស្រុកសំឡូត)។ | យុទ្ធនាការចុះប្រមូលកុមារចូលរៀន | | 5,420,600.00 | |

| | | | | | | |
|---|---|---|---|---|---|---|
| ១.៥. គាំទ្រទៅលើការបើកបវេសនកាលសម្រាប់សាលាគោលដៅទាំងអស់ (ស្រុកសំឡូត និងស្រុករុក្ខគិរី) | 1 | កម្មវិធីបិទបវេសនកាលចំនួន ១២ដងត្រូវបានធ្វើឡើងនៅក្នុងសាលាគោលដៅចំនួន ១២នៅក្នុងស្រុកសំឡូត ដែលមានអ្នកចូលរួមសរុបចំនួន ៤៨៦ នាក់ (ស្រី២៥៣នាក់) ក្នុងនោះមានដូចជា សិស្សានុសិស្ស, នាយក, គ្រូបង្រៀន, គណៈកម្មការទ្រទ្រង់សាលា, អាជ្ញាធរភូមិ ឃុំ និងសហគមន៍។<br><br>កម្មវិធីបើកបវេសនកាលចំនួន ២៨ដងបានកើតឡើងនៅក្នុងសាលារៀនគោលដៅចំនួន ២៨ (ស្រុករុក្ខគិរីចំនួន ១៥ និងស្រុកសំឡូតចំនួន ១៣) ដែលមានអ្នកចូលរួមសរុបចំនួន ១,៤២២នាក់ (ស្រី ៧៥១នាក់) ពិការចំនួន ៦នាក់ (ស្រី ៣នាក់), (អ្នកចូលរួមនៅក្នុងស្រុករុក្ខគិរីចំនួន ៨៦៤នាក់ (ស្រី ៤៣៥នាក់) និងសំឡូតចំនួន ៥៥៨នាក់ (ស្រី ៣១៦នាក់)) ក្នុងនោះមានដូចជា នាយកសាលា, គ្រូបង្រៀន, អាជ្ញាធរភូមិឃុំ, សហគមន៍ និងសិស្ស។ | រៀបចំទិវាបើកបវេសនកាលតាមសាលារៀនគោលដៅនីមួយៗ | | 2,374,600.00 | |
| ១.៥.គាំទ្រការវត្តវិភាគចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែង ETL ប្រចាំឆ្នាំ (SWOT) ជាមួយនឹងគ្រូ, គណៈកម្មការទ្រទ្រង់សាលា, នាយកសាលា , ឃុំ , តំណាងសិស្ស និងយុវជន (ស្រុកសំឡូត និង ស្រុករុក្ខគិរី) | 1 | ក្រុមការងារអង្គការខេនចំនួន ១៩នាក់ នឹងក្រុមយុវជនចំនួន ៤នាក់បានធ្វើការទស្សនៈកិច្ចសិក្សាទៅកាន់សាលារៀនវត្តបូរណ៍។ | ការចុះសិក្សារៀនសូត្រពីបទពិសោធន៍ ល្អៗពីសាលារៀនគំរូ | | 8,563,400.00 | |
| ១.៦.គាំទ្រការធ្វើផែនការអភិវឌ្ឍន៍សាលាតាមសាលានីមួយៗដោយមានការចូលរួមជាមួយអ្នកពាក់ព័ន្ធ សំខាន់ៗ, នាយកសាលា, គ្រូបង្រៀន, គណៈកម្មការទ្រទ្រង់សាលារៀន, ក្រុមប្រឹក្សាកុមារ និង ក្លឹបកុមារ (ស្រុកសំឡូត និង ស្រុករុក្ខគិរី) | 1 | ផែនការអភិវឌ្ឍន៍សាលាចំនួន ២៨ត្រូវបានបង្កើតឡើងនៅក្នុងសាលាគោលដៅចំនួន ២៨ (ទាំងក្នុងស្រុករុក្ខគិរី នឹងស្រុកសំឡូត) | មានផែនការអភិវឌ្ឍន៍សាលារៀនគ្រប់គោលដៅ | | 442,600.00 | |
| ១.៧. គាំទ្រកញ្ចប់ថវិការដើម្បីជួយដល់ការអភិវឌ្ឍន៍សាលារៀន (នៅពេលធ្វើផែនការអភិវឌ្ឍន៍សាលារៀន) នៅក្នុងសាលារៀនគោលដៅចំនួន ៣០ (ស្រុកសំឡូត និងស្រុករុក្ខគិរី) | 2 | សាលាគោលដៅចំនួន ៧ (ជំនាប់ក្រូចឆ្មា, ភ្នំព្រះ, រណ្ដៅបេ, ដីកំប៉ង់, ចុងពរ, ជំនាប់ស្នាច់ នឹងអូរច្រកថ្លាង) នៅក្នុងស្រុករុក្ខគិរីបានទទួលថវិកាខ្នាតតូច ១៥០ដុល្លាក្នុងការកែលម្អ/ អភិវឌ្ឍន៍សាលារៀន។ | ផ្ដល់ថវិកាខ្នាតតូច១៥០ដុល្លាដល់សាលាគោលដៅនីមួយៗ | | 4,200,000.00 | សកម្មភាពនេះនឹងបន្តធ្វើទៀតនៅ សប្តាហ៍ទី ៣ក្នុងខែ ធ្នូ ឆ្នាំ ២០១៨ |
| ១.៧.បំប៉ន/បណ្ដុះបណ្ដាលគណៈកម្មការទ្រទ្រង់សាលា និងក្រុមប្រឹក្សាឃុំសម្រាប់ស្ត្រី និងកុមារពីតួនាទី និងមុខងារ (ស្រុកសំឡូត និង ស្រុករុក្ខគិរី) | 1 | គណៈកម្មការទ្រទ្រង់សាលាចំនួន ១២៦នាក់ (ស្រី ២៣នាក់), ក្នុងនោះ ៦៩ នាក់នៅក្នុងស្រុកសំឡូត និង ៥៧ នៅក្នុងស្រុករុក្ខគិរី, នៅក្នុងសាលាគោលដៅចំនួន ២៨ (១៥ សាលានៅស្រុករុក្ខគិរី និង១៣សាលានៅស្រុកសំឡូត) បានទទួលវគ្គបំប៉នពីតួនាទី និងមុខងាររបស់គណៈកម្មការទ្រទ្រង់សាលារៀន និងការបង្កើតផែនការអភិវឌ្ឍន៍សាលារៀន។ | ពង្រឹងការពីតួនាទីនិងការងារគាំទ្រចូលរួមសម្រាប់សាលារៀន | | 4,022,700.00 | |

| | | | | | | |
|---|---|---|---|---|---|---|
| ១.៨. គាំទ្រព្រឹត្តិការណ៍ទិវាកុមារអន្តរជាតិ និងទិវាប្រឆាំងនឹងពលកម្មកុមារ (១ព្រឹត្តិការណ៍ក្នុង ១ឆ្នាំនៅតាមមូលដ្ឋានសាលានីមួយៗ, ថ្ងៃទី ១ ខែមិថុនា និង ថ្ងៃទី ១២ ខែមិថុនា), (ស្រុកសំឡូត និង ស្រុករុក្ខគិរី) | 1 | សាលារៀនគោលដៅចំនួន ២៣ (ទាំងក្នុងស្រុករុក្ខគិរី និងសំឡូត) បានប្រព្រឹត្តិ/ ធ្វើទិវាកុមារអន្តរជាតិ និងទិវាប្រឆាំងនឹងពលកម្មកុមារ។ អ្នកចូលរួមសរុបមានចំនួន ១,៤៧៤នាក់ (ស្រី ៧០៦នាក់)។ | រៀបចំទិវា១មិថុនា និង១២ មិថុនា តាមសាលាគោលដៅ | | 3,201,200.00 | |
| សកម្មភាពគោលទី ២:ពង្រឹង និងពង្រីកគុណភាពអប់រំនៅសាលាបឋមសិក្សា | | | គុណភាពអប់រំនៅបឋមសិក្សាត្រូវបានពង្រឹងនឹងពង្រីក | - | 15,872,600.00 | |
| ២.១. គាំទ្រការបង្កើតផែនទីសាលា/សិក្សាជាមួយនឹងការចូលរួមពីអ្នកពាក់ព័ន្ធសំខាន់ៗ (ស្រុកសំឡូត និង ស្រុករុក្ខគិរី) | 1 | ផែនទីសាលាត្រូវបានបង្កើតឡើងនៅក្នុងសាលារៀនគោលដៅចំនួន ១៥នៅស្រុករុក្ខគិរី និង ១៣នៅក្នុងស្រុកសំឡូត | ធ្វើផែនទីខ្នងសាលា តាមតំបន់គោលដៅ៣០សាលារៀន | | 247,000.00 | |
| ២.២. បំប៉ន/ បណ្តុះបណ្តាលគ្រូឧបសម្ព័ន្ធ (គ្រូបឋមសិក្សា), (ស្រុកសំឡូត និង ស្រុករុក្ខគិរី) | 1 | គ្រូបឋមសិក្សាចំនួន ២៩នាក់ (ស្រី ១១នាក់) នៅក្នុងស្រុករុក្ខគិរី និង ៩៨នាក់ (ស្រី ៧២នាក់) នៅក្នុងស្រុកសំឡូតបានទទួលវគ្គបំប៉នពីវិធីសាស្រ្តរៀន និងបង្រៀន, ការផលិតសម្ភារៈ, កិច្ចតែងការបង្រៀន នឹងកិច្ចការពារកុមារ។ | គ្រូចំនួន ១៥០នាក់បានទទួលបានការជួយបំប៉ន | | 8,055,200.00 | |
| ២.៣. ធ្វើការប្រជុំតាមកម្រងដោយផ្អែកទៅតាមកាលវិភាគ/ ពេលវេលាដែលបានព្រមព្រៀង (៧ ដងនៅសាលាកម្រង), (ស្រុកសំឡូត និង ស្រុករុក្ខគិរី) | 1 | ការប្រជុំចំនួន ៦៤ដងត្រូវបានធ្វើឡើងនៅក្នុងកម្រងគោលដៅចំនួន ១៤ (ស្រុករុក្ខគិរី និងស្រុកសំឡូត) ក្នុងនោះមាន នាយក និងគ្រូគោលដៅចំនួន ១១៤នាក់ (ស្រី ៦៥នាក់) បានចូលរួមនៅក្នុងការប្រជុំទាំង ១៤កម្រងនេះ។ | ប្រជុំបច្ចេកទេសតាមកម្រងទាំង ១២ សាលារៀន | | 1,933,100.00 | ១ ឆ្នាំ ប្រជុំ ៧ដង |
| ២.៤.គាំទ្រទៅលើការប្រជុំប្រចាំត្រីមាសជាមួយក្រុមអធិការកិច្ច (DTMT) ,នៅការិយាល័យអប់រំស្រុក ៣ដងក្នុង ១ឆ្នាំ (ស្រុកសំឡូត និង ស្រុករុក្ខគិរី) | 1 | ការប្រជុំប្រចាំត្រីមាសជាមួយក្រុមបំប៉នពិនិត្យតាមដាន និងវាយតម្លៃថ្នាក់ស្រុកចំនួន ៥ដងបានកើតឡើង (នៅក្នុងស្រុករុក្ខគិរីចំនួន ៤ដង នឹងស្រុកសំឡូតចំនួន ១ដង) ដែលមានអ្នកចូលរួមសរុបចំនួន ៥១នាក់។ ផែនការចុះត្រួតពិនិត្យតាមដាន និងវាយតម្លៃរបស់ក្រុម DTMT ត្រូវបានបង្កើតឡើងនៅក្នុងការប្រជុំ។ | ប្រជុំដើម្បីរៀបចំផែនការចុះត្រួតពិនិត្យ និងវាយតម្លៃតាមសាលារៀនគោលដៅ | | 446,100.00 | ការប្រជុំនេះកើតឡើងប្រចាំត្រីមាស |
| ២.៥.ពិនិត្យ និង កែលម្អផែនការអភិវឌ្ឍន៍សាលារៀនប្រចាំត្រីមាស (ស្រុកសំឡូត និង ស្រុករុក្ខគិរី) | 1 | ផែនការសាលារៀនចំនួន ១៥នៅក្នុងស្រុករុក្ខគិរី និង ១៣នៅក្នុងស្រុកសំឡូតត្រូវបានពិនិត្យជារៀងរាល់ត្រីមាសជាមួយ នាយកសលា,គណៈកម្មការ, គ្រូបង្រៀន និងអាជ្ញាធរភូមិឃុំ តាមសាលាគោលដៅនីមួយៗ។ | ប្រជុំតាមដាននិងកែរលម្អការងារប្រចាំត្រីមាស | | 574,000.00 | ការប្រជុំនេះកើតឡើងប្រចាំត្រីមាស |

| | | | | | | |
|---|---|---|---|---|---|---|
| ២.៦.គាំទ្រទៅលើការតាមដាន និងត្រួតពិនិត្យទៅដល់សាលាមូលដ្ឋានប្រចាំខែ (ស្របជាមួយនឹងផែនការដែលបានព្រមព្រៀង), ទាំងក្នុងស្រុករុក្ខគិរី និងស្រុកសំឡូត | 1 | ការប្រជុំពីការរៀបចំការជួលជុល នឹងធ្វើបង្គន់បានចំនួន ២ដងនៅក្នុងសាលាទ្រូងខ្លា និងភ្នំរៃ ស្រុកសំឡូត។<br>នៅក្នុងស្រុកសំឡូតបានប្រជុតាមដាន និងត្រួតពិនិត្យផែនការសាលាបានចំនួន ៨ ដងនៅក្នុង ៦សាលាគោលដៅ ដែលមានអ្នកចូលរួមសរុបចំនួន ១១៤នាក់ (ស្រី ៦២នាក់)។ និងនៅក្នុងស្រុករុក្ខគិរីបានចំនួន ១២ដងនៅក្នុង ៨សាលាសហគមន៍ ដែលមានអ្នកចូលរួមសរុបចំនួន ១៧៨នាក់ (ស្រី ៤៦នាក់)។ | ប្រជុំតាមដាននិងកែរលម្អការងារប្រចាំខែ | | 655,800.00 | |
| ២.៧. ផ្តល់សម្ភារៈរៀន និងកង់ទៅដល់សិស្សពិការ/ពិបាកក្នុងការទៅរៀនចំនួន ៩៦នាក់ (ស្រុករុក្ខគិរី និងសំឡូត) | 2 | យើងនឹងផ្តល់សម្ភារៈសិក្សា និងកង់ទៅដល់សិស្សពិការ និងសិស្សពិបាកក្នុងការសិក្សាចំនួន ៤៨ នាក់នៅក្នុងសាលាគោលដៅចំនួន ១៥ នៅក្នុងស្រុករុក្ខគិរី នៅសប្តាហ៍ទី ៣ ខែធ្នូ ឆ្នាំ ២០១៨។ | ផ្តល់ឃីតសិក្សាដល់ស្សិពិការ | | | នឹងផ្តល់អោយក្នុងសប្តាហ៍ទី ៣ខែ ធ្នូ ឆ្នាំ ២០១៨ |
| ២.៨. ផ្តល់សម្ភារៈសិក្សាទៅដល់សិស្សសាលាសហគមន៍គោលដៅចំនួន ២០សាលានៅស្រុករុក្ខគិរី និងស្រុកសំឡូត | 2 | សិស្សចំនួន ៨៦៣នាក់ នៅក្នុងសាលាគោលដៅចំនួន ១១ (ជីកំប៉ង់, ចុងពរ, ពងទឹក, បឹងអំពិល, ភ្នំព្រះ, អូរច្រកថ្លាង នឹងបឹងចក) នៅក្នុងស្រុករុក្ខគិរីបានទទួលសម្ភារៈសិក្សាចំនួន ៨៦៣ឃីត (ក្នុង ១នាក់ទទួលបាន ១ឃីតសិក្សា)។ សម្ភារៈសិក្សារួមមានៈ សៀវភៅសរសេរ, ប៊ិច, ខ្មៅដៃ, ជ័រលុប, ប្រដាបខ្វង នឹងបន្ទាត់។<br><br>នៅសប្តាហ៍ទី ៣ខែធ្នូ ឆ្នាំ ២០១៨, សម្ភារៈសិក្សាចំនួន ៣,០៩៨សិត ត្រូវបានផ្តល់ទៅអោយសិស្សចំនួន ១,៤៨២ នៅក្នុងសាលាគោលដៅចំនួន ១៣នៅស្រុកសំឡូត និង ១,៦១៦នៅក្នុងសាលាគោលដៅចំនួន ១៥ នៅស្រុករុក្ខគិរី។ | សិស្សទាំងអស់ក្នុងសាលាគោលដៅទាំង២០ | | 3,961,400.00 | នឹងផ្តល់អោយក្នុងសប្តាហ៍ទី ៣ខែ ធ្នូ ឆ្នាំ ២០១៨ |
| **១.៤ ការពង្រីកការអប់រំក្រៅប្រព័ន្ធ** | | | | **-** | **5,548,800.00** | |
| សកម្មភាពគោលទី ២: ការអភិវឌ្ឍនិងពង្រីកការអប់រំក្រៅប្រព័ន្ធ | | | សិក្ខាសាលាមាតាបិតា ត្រូវបានធ្វើឡើងនៅក្នុងសាលារៀន/ភូមិចំនួន ៣០ ពីកម្មវិធីមាតាបិតាល្អនិងការថែទាំកូន។ ហើយក៏ជាមាតាបិតាគំរូទៅលើគុណតម្លៃនៃការអប់រំ និងការការពារកុមារ/ កិច្ចការពារ កុមារ។ | - | 5,548,800.00 | |

| | | | | | | |
|---|---|---|---|---|---|---|
| ១.១. គាំទ្រទៅលើសិក្ខាសាលាពីមាតាបិតាថៃទាំកូនពីការគាំទ្រ និងថៃរក្សាកូនរបស់ពួកគេ (ប្រចាំត្រីមាស), ស្រុករុក្ខគិរី និងស្រុកសំឡូត | 1 | ក្រុមអាណាព្យាបាលគំរូចំនួន ២៨ក្រុម ដែលមានសមាជិកចំនួន ៦៣២នាក់ (ស្រី ៤២៩នាក់) បានបង្កើតឡើងនៅក្នុងសាលាគោលដៅចំនួន ១៥ នៅក្នុងស្រុករុក្ខគិរី និងសាលាគោលដៅចំនួន ១៣នៅក្នុងស្រុកសំឡូត។ វគ្គសិក្ខាសាលាបំប៉នពីការគាំទ្រកូន ការចិញ្ចឹមកូនបែបវិជ្ជមាន និងថៃទាំកូនត្រូវបានធ្វើឡើងចំនួន ៣៨ដងនៅសាលាគោលដៅ (នៅក្នុងស្រុករក្ខគិរីចំនួន ១៥សាលា និងស្រុកសំឡូតចំនួន ១៣សាលាគោលដៅ) ដែលមានអ្នកចូលរួមសរុបចំនួន ៩៣៩នាក់ (ស្រី ៦៤៩នាក់) | ក្រុមមាតាបិតាគំរូនិងជួយការសិក្សារបស់កូន (៣០ក្រុម) | | 5,548,800.00 | |
| **១.៥ ការពង្រឹង និងការពង្រីកកម្មវិធីលើកកម្ពស់សុខភាពសិក្សា** | | | | - | 7,748,900.00 | |
| សកម្មភាពគោលទី ១ :ការពង្រឹងអង្គភាព និងការពិនិត្យតាមដាន | | | សមត្ថភាពការបំពេញការងារអប់រំសុខភាពសិក្សាត្រូវបានពង្រឹង | - | 540,600.00 | |

| | | | | | | |
|---|---|---|---|---|---|---|
| ១.១ គាំទ្រការបញ្ជូនកុមារងាយរងគ្រោះទៅរកសេវាព្យាបាលទាំងស្រុកសំឡូត និងស្រុករុក្ខគិរី | 1 | ខេនបានអន្តរាគមន៍កុមារីបានចំនួន ១៥នាក់:<br>១. ជីតាយកទៅធ្វើចំការជាមួយ (មិនអោយទៅរៀន)<br>(បច្ចុប្បន្នកុមារដែលជីតាទៅធ្វើចំការជាមួយបានចូលរៀនទៀងទាត់វិញហើយ )<br>២. ឳពុកម្តាយបោះបង់ចោល<br>(បច្ចុប្បន្នមានអ្នកយកទៅចិញ្ចឹម ហើយខេនបាន ផ្តល់ជាអាហាររូបត្ថម្ភ<br>៣. បញ្ហាខូចចលករប្រសាទ (ទន់)<br>(បានទៅទទួលថ្នាំ នឹងរទេះគាបរួចរាល់ហើយ)<br>៤. កុមារ ៣នាក់មិនមានផ្ទះសំបែងត្រឹមត្រូវ និងមិនមានអាហាររូបត្ថម្ភគ្រប់គ្រាន់ (បច្ចុប្បន្នកុមារទាំង ៣នាក់បានទទួលផ្ទះសម្រាប់សម្រាកសមរម្យដោយមានការបដិភាគពីសហគមន៍ ព្រះសង្ឃ និងអង្គការ World Vision។ ហើយខេនបានផ្តល់ជាអាហាររូបត្ថម្ភ និងសម្ភារៈប្រើប្រាស់ក្នុងផ្ទះខ្លះៗ)។ បច្ចុប្បន្នកុមារទាំង ៣នាក់បានទៅរៀនទៀតទាត់នៅសាលាស្តុកប្រវឹក។<br>៥. កុមារ ៣នាក់មានបញ្ហាខូចចលកប្រសាទ (ទន់) (បច្ចុប្បន្នកុមារបានបញ្ជូនទៅមណ្ឌលស្តាររួចហើយ កំពុងតែពិនិត្យ)<br>៦. កុមារ ១នាក់មានបញ្ហាសតិអារម្មណ៍,គម្រោងបានបញ្ជូនទៅមណ្ឌលសុខភាពអន្លង់វិល (បច្ចុប្បន្នកុមារបានធូគ្រាន់បើហើយ ព្រោះប្រើប្រាស់ថ្នាំជាប្រចាំ)<br>៧. កុមារ ២នាក់មានបញ្ហាខូលចលកប្រសាទ (ទន់ ប៉ុន្តែកំរិតមធ្យម),គម្រោងបានបញ្ជូនទៅមណ្ឌលស្តារ (បច្ចុប្បន្នកុមារទាំងពីរនាក់បានទទួលជើងអបរួចរាល់ | ករណីកុមារមានបញ្ហានិងគ្រោះថ្នាក់ បន្ទាន់ | | 540,600.00 | សកម្មភាពនេះកើតឡើងជាប្រចាំនៅពេលកុមារត្រូវការ សេវាព្យាបាល |

| | | | | | | |
|---|---|---|---|---|---|---|
| | | ៨. កុមារមានកើតមិនគ្រប់ខែហើយកុមារមានសុខភាពមិនសូវល្អ,និងមានមាន ១.៦k.g(មួយគីឡូ ប្រាំមួយខាំ) យោងតាមពេទ្យមណ្ឌល់សុខភាពឃុំអោយបញ្ជូនកុមាររកសេវាព្យាបាលនិងថែទាំ។ គម្រោងបានបញ្ជូនទៅមន្ទីពេទ្យគន្ធបុប្ផានៅខេត្តសៀមរាបនៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៨, បច្ចុប្បន្នកុមារបានត្រឡប់មកផ្ទះវិញដោយសុវត្ថិភាព។<br>៩. កុមារាបានធ្លាក់ពីលើគ្រែសង្ស័យបាក់ឆ្អឹងដែបានបញ្ជូនទៅពិនិត្យនិងព្យាបាលនៅមន្ទីពេទ្យអ៊ុមេចិនស៊ីនៅខេត្តបាត់ដំបងនៅថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៨។ កុមារមិនបាក់ឆ្អឹងទេគ្រាន់តែបាក់សាច់ដុំ,លោកគរូពេទ្យបានអោយកុមារត្រឡប់ទៅផ្ទះពេទ្យអោយថ្នាំមកព្យាបាលនៅផ្ទះ,កុមារបានគ្រាន់ជាងមុន ,កុមារមករៀនធម្មតា។<br>១០. កុមារាមានបញ្ហាពិការជើង (ដើរមិនរួច, រឹងឆ្អឹង) រស់នៅភូមិដូនត្រិត បានបញ្ជូនទៅព្យាបាលនៅមណ្ឌលស្តារខេត្តបាត់ដំបងនៅថ្ងៃទី ១៥ និងទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨។ ពេទ្យបានតំរង់ជើងគាត់អោយត្រង់ ហើយងាយស្រួលជាងមុន ប៉ុន្តែនៅតែមិនអាចដើរ (គ្រាន់ជាងមុនបន្តិច)។<br>១១. កុមារីមានបញ្ហាស្រឡេវភ្នែក រស់នៅភូមិដូនត្រិត, គម្រោងបានបញ្ជូនទៅពេទ្យភ្នែកនៅបាត់ដំបងនៅថ្ងៃទី ១៥ នឹងថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០១៨។ កុមារបានគ្រាន់ជាងមុន ប៉ុន្តែមិនអាចជាទាំងស្រុងទេ។ | | | | |
| សកម្មភាពគោលទី ២:ការអភិវឌ្ឍ និងការលើកកម្ពស់សុខភាពសិក្សា | | | សាលាគោលដៅមានទឹកស្អាតសម្រាប់ញុំា និងមានអនាម័យ | - | 7,208,300.00 | |
| ២.១. ផ្តល់ធុងចម្រោះទឹកស្អាតទៅសាលាគោលដៅចំនួន ៣០សាលា (ស្រុករុក្ខគិរី និងស្រុសំឡូត) | 1 | ធុងចម្រោះចំនួន ៣០បានផ្តល់ទៅអោយសាលាគោលដៅចំនួន ១៥សាលា នៅក្នុងស្រុករុក្ខគិរី | សាលាទាំង៣០ទទួលបានធុងចំរោះទឹក សម្រាប់ញាំតាមថ្នាក់រៀន | | 4,638,000.00 | នៅក្នុងស្រុកសំឡូតនឹងផ្តល់អោយនៅក្នុងត្រីមាសទី ៤ |
| ២.២. ផ្តល់សម្ភារៈអនាម័យទៅដល់សាលាគោលដៅចំនួន ៣០សាលា (ស្រុករុក្ខគិរី និងស្រុកសំឡូត) | 1 | សម្ភារៈអនាម័យ (ធុង ឬប៉ោតដងទឹក ផ្តិលដងទឹក ចានទ្រាប់ ទឹកលាងបង្គន់ អំបោលដងវែង កន្សែងជូតដៃ ច្រាសដុះចានបង្គន់ កូនកន្ត្រកដាក់សាប៊ូ កន្ត្រកដាក់សំរាម និងអំបោលធាងដូង) ចំនួន ១០សិតបាន ផ្តល់ទៅអោយសាលាគោលដៅចំនួន ១០សាលានៅក្នុងស្រុករុក្ខគិរី។ | សាលា៣០ទទួលបាសម្ភារៈអនាម័យនិងសំអាតបរិស្ថានសាលា | | 1,448,400.00 | សម្រាប់សំឡូត និងផ្តល់អោយនៅក្នុងត្រីមាសទី ៤ |

| | | | | | | |
|---|---|---|---|---|---|---|
| ២.៣. គាំទ្រការប្រជុំលើកកំពស់ការយល់ដឹងពីអនាម័យជារៀងរាល់ ៣ ខែ ម្តង (បង្កើនការយល់ដឹងដល់សមាជិកក្លឹបកុមារ និងសិស្សសាលា)នៅក្នុងសាលាគោលដៅនៅក្នុងស្រុករុក្ខគិរី និងស្រុកសំឡូត | 1 | ខេនបានសហការជាមួយនាយកសាលា, គ្រូបង្រៀនក្នុងការប្រជុំលើកកម្ពស់ការយល់ដឹងពីអនាម័យ, សិទ្ធកុមារ និងកិច្ចការពារកុមារបានចំនួន ៤៣ដង នៅក្នុងសាលារៀនគោលដៅចំនួន ២៨ (១៥ សាលាគោលដៅនៅក្នុងស្រុករុក្ខគិរី និង ១៣សាលាគោលដៅនៅក្នុងស្រុកសំឡូត)។ ក្នុងនោះមានអ្នកចូលរួមចំនួន ១,៤៧១នាក់ (ស្រី ៧០៣នាក់)។ | ក្នុងសាលារៀនគោលដៅពីសកម្មភាពសុខភាពអនាម័យសាលារៀន | | 1,121,900.00 | |
| **ឈ្មោះសកម្មភាព ក្នុងផែនការ** | **ស្ថាន<br>ភាព** | **លទ្ធផលសម្រេច ( ធាតុចេញ )** | **លទ្ធផលរំពឹងទុក** | **ថវិកាបានអនុវត្ត**<br>**រដ្ឋ** | <br>**ដៃគូ** | **សេចក្តី<br>បញ្ជាក់** |
| **កម្មវិធីទី៤៖ ការអភិវឌ្ឍជំនាញបច្ចេកទេសនិងជំនាញទន់សម្រាប់យុវជន** | | | | - | **12,734,500.00** | |
| ៤.១ ពង្រឹងសកម្មភាពភាពយុវជន | | | | - | 12,734,500.00 | |
| សកម្មភាពគោលទី ១ គាំទ្រអង្គភាព និងការពិនិត្យតាមដាន | | | ក្រុមគោលដៅចំនួន ២៧ (យុវជនសម្រាប់ការគាំទ្រផ្នែកអប់រំ) ត្រូវបានបណ្តុះបណ្តាល និងមានវិធីសាស្ត្រដើម្បីជួយដល់កុមារដែលក្រីក្រហើយមានបញ្ហាក្នុងការរៀន/ រៀនយឺត និងកុមារពិការ។ សាលារៀនចំនួន ២៧ត្រូវបានតាមដាន និងគាំទ្រសម្រាប់កុមារដែលរៀនយឺត/ ខ្សោយ និងកុមារពិការដោយក្រុមយុវជន។ | - | 4,704,700.00 | |
| ១.១. បំប៉ន/ បណ្តុះបណ្តាលទៅដល់ក្រុមយុវជនពីសិទ្ធកុមារ/ កិច្ចការពារកុមារ, ពិការភាព, ភាពជាអ្នកដឹកនាំ និងការសម្របសម្រួល នៅក្នុងភូមិ/ សាលាគោលដៅ (ស្រុករុក្ខគិរី និងស្រុកសំឡូត) | 1 | ក្រុមយុវជនចំនួន ២៨ក្រុម (១៣ ក្រុមនៅស្រុកសំឡូត និង ១៥ ក្រុមនៅស្រុករុក្ខគិរី) បានចូលរួមវគ្គបណ្តុះបណ្តាលពីសិទ្ធកុមារ កិច្ចការពារកុមារ ការសម្របសម្រួល សិទ្ធជនពិការ ប្រភេទនៃពិការភាព ការបង្រៀនកុមារដែលរៀនខ្សោយ និងកុមារពិការ នៅក្នុងសាលា/ ចំនុច/ភូមិគោលដៅចំនួន ២៨ សាលា។ កុមារពិការចំនួន ៤៧នាក់ (ស្រី ២៨នាក់) បានកំណត់/ ស្វែងរកឃើញនៅក្នុងសាលា/ ភូមិ/ ចំនុចគោលដៅចំនួន ២៨។ | ក្លឹបយុវជមិត្តជួយមិត្តបានយល់ដឹងពីការងារជួយកុមារពិការក្នុងការសិក្សារ និងដឹកនាំក្លឹបកុមារផ្សព្វផ្សាយពីសិទ្ធិកុមារនិងកុមារពិការ | | 4,704,700.00 | |

| | | | | | | |
|---|---|---|---|---|---|---|
| សកម្មភាពគោលទី២ ការអភិវឌ្ឍគោនយោបាយ សមត្ថភាព និងជំនាញយុវជន | | | វគ្គបណ្តុះបណ្តាលដល់ក្រុមយុវជនចំនួន ៤២ដង ក្នុង ២៧សាលាគោលដៅ។យុវជនចំនួន ១៣៥នាក់បានចូលរួម និង ផ្តល់ការគាំទ្រជាទៀងទាត់ទៅការប្រជុំក្លឹបកុមារ។ក្រុមគោលដៅចំនួន ២៧ (យុវជនសម្រាប់ការគាំទ្រផ្នែកអប់រំ) ត្រូវបានបណ្តុះបណ្តាល និងមានវិធីសាស្ត្រដើម្បីជួយដល់កុមាររៀនខ្សោយ/ រៀនយឺត និងកុមារពិការ។ សាលារៀនចំនួន ២៧ត្រូវបានតាមដាន និងគាំទ្រសម្រាប់កុមារដែលរៀនយឺត/ ខ្សោយ និងកុមារពិការដោយក្រុមយុវជន។ | 0 | 8,029,800.00 | |
| ២.១. ផ្តល់សម្ភារៈពីសិទ្ធកុមារ និងកិច្ចការពារកុមារទៅដល់ក្រុមយុវជនចំនួន ២៧ក្រុម | 1 | បានផ្តល់យីតសម្រាប់ផ្សព្វផ្សាយពីសិទ្ធកុមារ, កិច្ចការពារកុមារ, ការបង្រៀនសិស្សពិការ និងសិស្សរៀនយឺតចំនួន ២៨យីតទៅដល់ក្រុមមិត្តអប់រំមិត្តចំនួន ២៨ក្រុមនៅក្នុងសាលាគោលដៅចំនួន ២៨ (នៅស្រុករុក្ខគិរីចំនួន១៥សាលា និងសំឡូតចំនួន ១៣សាលា)។ | ក្រុមយុវជន ២៧ក្រុមនៅក្នុង ២៧សាលារៀនគោលដៅបានទទួលយីតសម្រាប់ផ្សព្វផ្សាយពីសិទ្ធកុមារ, ការបង្រៀនសិស្សពិការ និងសិស្សរៀនខ្សោយ | | 3,507,900.00 | |
| ២.២ ផ្តល់សម្ភារៈក្លឹបកុមារទៅដល់ក្លឹបកុមារដើម្បីយកទៅផ្សព្វផ្សាយ | 1 | បានផ្តល់យីតសម្រាប់ផ្សព្វផ្សាយពីសិទ្ធកុមារ និងកិច្ចកុមារកុមារទៅដល់ក្រុមក្លឹបកុមារចំនួន ២៨ក្រុមនៅក្នុងសាលាគោលដៅចំនួន ២៨ (នៅស្រុករុក្ខគិរីចំនួន១៥សាលា និងសំឡូតចំនួន ១៣សាលា)។ | ក្លឹបកុមារ៣០សាលារៀនគោលដៅទទួលបានយីតសម្រាប់ផ្សព្វផ្សាយពីសិទ្ធិកុមារនិងការសិក្សារ | | 3,400,000.00 | |
| ២.៣ គាំទ្រការប្រជុំលើកកំពស់ការយល់ដឹងពីសិទ្ធកុមារ/ កិច្ចការពារកុមារជារៀងរាល់ ៣ ខែម្តង (បង្កើនការយល់ដឹងដល់សមាជិកក្លឹបកុមារ និងសិស្សសាលា) | 1 | ខេនបានសហការជាមួយនាយកសាលា, គ្រូបង្រៀនក្នុងការប្រជុំលើកកម្ពស់ការយល់ដឹងពីអនាម័យ, សិទ្ធកុមារ និងកិច្ចការពារកុមារបានចំនួន ៤៣ដងនៅក្នុងសាលារៀនគោលដៅចំនួន ២៨ (១៥ សាលាគោលដៅនៅក្នុងស្រុករុក្ខគិរី និង ១៣សាលាគោលដៅនៅក្នុងស្រុកសំឡូត)។ ក្នុងនោះមានអ្នកចូលរួមចំនួន ១,៤៧១នាក់ (ស្រី ៧០៣នាក់)។ | ផ្សព្វផ្សាយការយល់ដឹង ពីសិទ្ធិកុមារ(កូនល្អ សិស្សល្អ មិត្តល្អ ប្រជាពលរដ្ឋល្អ) | | 1,121,900.00 | |
| **ឈ្មោះសកម្មភាព ក្នុងផែនការ** | **ស្ថានភាព** | **លទ្ធផលសម្រេច ( ធាតុចេញ )** | **លទ្ធផលរំពឹងទុក** | **ថវិកាបានអនុវត្ត**<br>**រដ្ឋ** | <br>**ដៃគូ** | **សេចក្តីបញ្ជាក់** |
| **កម្មវិធីទី៥៖ ការគាំទ្រសេវាអប់រំ និងអភិបាលកិច្ចល្អ** | | | | - | **1,242,201,500.00** | |
| **៥.៥ ការវាយតម្លៃលទ្ធផលសិក្សា និងអធិការកិច្ចគុណភាពអប់រំ** | | | | - | **1,299,300.00** | |

| | | | | | | |
|---|---|---|---|---|---|---|
| សកម្មភាពគោលទី ២. អធិការកិច្ច និងការស្រាវជ្រាវបច្ចេកទេសគុណភាពអប់រំ | | | គុណភាពអប់រំត្រូវបានកែលម្អជាប្រចាំ | - | 1,299,300.00 | |
| ១.១ គាំទ្រទៅដល់ក្រុមអធិការកិច្ច (DTMT) ធ្វើការត្រួតពិនិត្យប្រចាំខែនៅសាលាគោលដៅចំនួន ១៤សាលា (ស្រុករុក្ខគិរី និងស្រុកសំឡូត) | 1 | ក្រុមបំប៉នពិនិត្យតាមដាន និងវាយតម្លៃថ្នាក់ស្រុក បានចុះទៅពិនិត្យការងាររៀន និងបង្រៀន ការគាំពារបានចំនួន ១៨សាលា (១៥សាលានៅស្រុករុក្ខគិរី និង ៣សាលានៅស្រុកសំឡូត) | ក្រុមអធិការកិច្ច (DTMT) នឹងធ្វើការចុះត្រួតពិនិត្យគាំទ្រ ទៅសាលាគោលដៅចំនួន ១៤ សាលារៀនកម្រង (ស្រុករុក្ខគិរី និងស្រុកសំឡូត) | | 1,299,300.00 | |
| **៥.៩ ការពង្រឹងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធអប់រំ** | | | | **-** | **1,240,902,200.00** | |
| សកម្មភាពគោលទី ២ ការអភិវឌ្ឍអគារសិក្សា និងហេដ្ឋារចនាសម្ព័ន្ធអប់រំ | | | ជួសជុលកែលម្អ និងសាងសង់ថ្មីសាសាលរៀនឧបសម្ព័ន្ធជនបទ ។ ការងារថែទាំ ជួសជុល និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធអប់រំត្រូវបានលើកលើកកម្ពស់ទាំងគុណភាពទាំងបរិមាណ តាមបែបសាលាកុមារមេត្រី | - | 1,240,902,200.00 | |
| ២.១ ការបង្កើតការរចនាសាលា និងការកំណត់យកការរចនា (សាលាគោលដៅនៅស្រុកសំឡូត និងរុក្ខគិរី) | 1 | ប្លង់សាលាត្រូវបានបង្កើត ហើយបានឯកភាពពីខាងសាលាស្រុក, អប់រំស្រុក នឹងឃុំអោយសាងសង់សាលាទៅតាមប្លង់នឹង។ | កៀងគររកធនធានបដិភាគពីសហគមន៍ | | 406,500.00 | |

| | | | | | | |
|---|---|---|---|---|---|---|
| ២.២ សាងសង់សាលាមត្តេយ្យ និង សាលាឧបសម្ព័ន្ធសហគមន៍ចំនួន ១០សាលា (ស្រុកសំឡូត និងស្រុករុក្ខគិរី), និងជួសជុលសាលារៀនចំនួន ២ (ស្រុកសំឡូត និងស្រុករុក្ខគិរី) | 1 | ខេនបានសាងសង់សាលាចំនួន ១០ (មានចំនួន ២៤បន្ទប់) នឹងជួលជុលសាលារៀន ១ (១បន្ទប់) នឹងជួសជុលយ៉ាបបាន ១ (៣បន្ទប់)នៅស្រុករុក្ខគិរីៈ<br>១. អូរច្រកថ្លាង (២បន្ទប់) សម្រេចបាន ១០០%<br>២.ប៉ាហាល (២បន្ទប់) សម្រេចបាន ១០០%<br>៣. ធ្នួយ (២បន្ទប់) សម្រេចបាន ១០០%<br>៤. បឹងអំពិល (៣បន្ទប់) សម្រេចបាន ១០០%<br>៥. បឹងចក (៣បន្ទប់) សម្រេចបាន ១០០%<br>៦. ថ្មំ (៣បន្ទប់) សម្រេចបាន ១០០%<br>៧. ត្រជាក់ចិត្ត (៣បន្ទប់) សម្រេចបាន ១០០%<br>៨. ជីកំប៉ង់ ជួសជុល ១បន្ទប់ សម្រេចបាន ១០០%<br>៩. ជំនាបស្អាច់ជួសជុលយ៉ាបសាលាបាន ១ខ្នង (៣បន្ទប់) សម្រេចបាន ១០០%<br>១០. ជំនាប់គគីរ (៣បន្ទប់) សម្រេចបាន ១០០%<br>១១. កែវមុន្នី (៣បន្ទប់) សម្រេចបាន ១០០%<br>១២. ពងទឹក (១ បន្ទប់) សម្រេចបាន ១០០% | សាលារៀនចំនួន១០កន្លែង ដោយមានថ្នាក់មេត្តេយ្យ | | 979,117,300.00 | |
| | | ខេនបានសាងសង់សាលាចំនួន ១២ (មានចំនួន ៣២បន្ទប់) នៅស្រុកសំឡូតៈ<br>១. ស្រែពន្លក (៣បន្ទប់) សម្រេចបាន ១០០%<br>២. ឆ្កោងក្រៅ (៣បន្ទប់) សម្រេចបាន ១០០%<br>៣. កំពង់ត្រាំង (៣បន្ទប់) សម្រេចបាន ៦០%<br>៤. សែន សុខ (៣បន្ទប់) សម្រេចបាន ១០០%<br>៥. អូរថ្មរុងរឿង (៣បន្ទប់) សម្រេចបាន ១០០%<br>៦. ដូនត្រិតកណ្ដាល (៣បន្ទប់) សម្រេចបាន ១០០%<br>៧. អូរអន្សង (៣បន្ទប់) សម្រេចបាន ១០០%<br>៨. បុស្សរកា (៣បន្ទប់) សម្រេចបាន ១០០%<br>៩. វាលធ្នារ (៣បន្ទប់) សម្រេចបាន ១០០%<br>១០. ព្រៃឫស្សី (៣បន្ទប់) សម្រេចបាន ១០០%<br>១១.ច្រកចង្អៀត (១ បន្ទប់) សម្រេចបាន ១០០%<br>១២. ចំការស្រូវ (១បន្ទប់) សម្រេចបាន ១០០% | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | 1 | ខេនបានសាងសង់បង្គន់ចំនួន ៨ (១៦បន្ទប់) នៅស្រុករុក្ខគិរីៈ<br>១. ជំនាប់ស្នាច់ សម្រេចបាន ១០០%<br>២. ប៉ាហាល សម្រេចបាន ១០០%<br>៣. ធ្នួយ សម្រេចបាន ១០០%<br>៤. បឹងអំពិល សម្រេចបាន ១០០%<br>៥. បឹងចក សម្រេចបាន ១០០%<br>៦. ថ្មំ សម្រេចបាន ១០០%<br>៧. ត្រជាក់ចិត្ត សម្រេចបាន ១០០%<br>៨. ជំនាប់គគីរ សម្រេចបាន ១០០%<br><br>ខេនបានសាងសង់បង្គន់ចំនួន ១១ (២២បន្ទប់) នឹងជួលជុលបង្គន់ចំនួន ២ (៤ បន្ទប់) នៅស្រុកសំឡូតៈ<br>១. ទ្រូងខ្លា សាងសង់សម្រេចបាន ១០០%<br>២. ឆ្អោងក្រៅ សាងសង់សម្រេចបាន ១០០%<br>៣. កំពង់ត្រាំង សាងសង់សម្រេចបាន ១០០%<br>៤. ស្រែពន្លក សាងសង់សម្រេចបាន ១០០%<br>៥. សែន សុខ សម្រេចបាន ១០០%<br>៦. អូរថ្មរុងរឿង សម្រេចបាន ១០០%<br>៧. ដូនត្រិតកណ្តាល សម្រេចបាន ១០០%<br>៨. ភ្នំរៃ ជួសជុលសម្រេចបាន១០០%<br>៩. ព្រៃឫស្សី សាងសង់សម្រេចបាន ១០០%<br>១០. អូរអន្សង សាងសង់សម្រេចបាន ១០០%<br>១១.បុស្សរកា សាងសង់សម្រេចបាន ១០០%<br>១២. វាលធ្នា សាងសង់សម្រេចបាន ១០០% | | | | |
| ២.៣ តំឡើងប្រព័ន្ធប្រមូលទឹកភ្លៀង, ធ្វើសួនកុមារ និង សាងសង់/ជួលជុលបង្គន់ចំនួន ១៤សាលារៀនគោលដៅ (ស្រុកសំឡូត និងស្រុករុក្ខគិរី) | | | បំពាក់ប្រព័ន្ធត្រងទឹកភ្លៀងតាមសាលារៀន និងសួនកំសាន្តសម្រាប់កុមារលេងកន្លែង | | 260,350,000.00 | |
| | 1 | ខេនបានធ្វើសួនកុមារចំនួន ៩ នៅស្រុករុក្ខគិរីៈ (អូរច្រេកថ្លាង, ប៉ាហាល, ធ្នួយ, បឹងអំពិល, បឹងចក, ជំនាប់ស្នាច់, រណ្តៅបេ, ដីកំប៉ង និងជំនាប់ក្រូចឆ្មា) សម្រេចបាន ១០០%។ | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | 1 | ខេនបានធ្វើប្រព័ន្ធប្រមូលទឹកភ្លៀងដែលមានចំណុះ ៩០០០លីត្រចំនួន ៩ សាលា: (អូរច្រកថ្លាង, ផ្ទួយ, បឹងអំពិល, បឹងចក, ជីកំប៉ង់, ប៉ាលហាល, ភ្នំព្រះ, ពងទឹក និងចុងពរ) ។ ក្នុងនោះក៏មានកន្លែងលាងដៃភ្ជាប់ជាមួយដែរ។ នៅក្នុងសាលាចំនួន ៣សាលាដែលដាក់ពាងយក្ស (ជំនាប់ស្នាច់, រណ្តៅបេ និង អូររំចេក)។ នៅសាលាជំនាប់ក្រូចឆ្មា បានធ្វើកន្លែងលាងដៃសម្រេចបាន ១០០% ។<br>ខេនបានធ្វើប្រព័ន្ធប្រមូលទឹកភ្លៀងដែលមានចំណុះ ១៤០០០លីត្រចំនួន ១ សាលា (សែន សុខ) សម្រេចបាន ១០០%។ | | | | |
| ២.៤ គាំទ្រសហការ បច្ចុប្បន្នភាព គណៈកម្មការត្រួតពិនិត្យអាគារសាលារៀន (នៅក្នុងសាលារៀនគោលដៅចំនួន ៣០សាលាទាំងស្រុករុក្ខគិរី និងស្រុកសំឡូត) | 1 | គណៈកម្មការត្រួតពិនិត្យការសាងសង់សាលាសហគមន៍ឧបសម្ព័ន្ធបានធ្វើការត្រួតពិនិត្យ នឹងវាយតម្លៃសាលាបានចំនួន ១១សាលា (ទាំងក្នុងស្រុករុក្ខគិរី នឹងសំឡូត)។ | គណៈកម្មការត្រួតពិនិត្យការងារសាងសង់សាលាសហគមន៍ឬឧបសម្ពន្ធ | | 514,200.00 | |
| ២.៥ គាំទ្រការត្រួតពិនិត្យបច្ចេកទេសជាទៀងទាត់ (សម្រាប់ក្រុមគណៈកម្មការទ្រទ្រង់សាលា) នៅក្នុងសាលារៀនគោលដៅចំនួន ៣០សាលាស្រុករុក្ខគិរី និងស្រុកសំឡូត | 1 | គណៈកម្មការត្រួតពិនិត្យការសាងសង់សាលាសហគមន៍ឧបសម្ព័ន្ធបានធ្វើការត្រួតពិនិត្យ នឹងវាយតម្លៃសាលាបានចំនួន ១១សាលា (ទាំងក្នុងស្រុករុក្ខគិរី នឹងសំឡូត)។ | គណៈកម្មការទ្រទ្រងសាលារៀន ទាំង៣០ សាលា | | 514,200.00 | |
| ២.៦ ពិនិត្យមើលបច្ចេកទេសជាក់លាក់ឡើងវិញ, ការរចនា, តម្លៃ និងកិច្ចព្រមព្រៀងជាមួយដៃគូដែលបានកំណត់។ (ប្រព័ន្ធត្រងទឹកភ្លៀង, កន្លែងលាងដៃ, បង្គន់ និងសួនកុមារ) | 1 | ក្រុមការងារ RWC បានចុះមកពិនិត្យមើលធុងទឹក នឹងទឹកន្លែងសាងសង់ធុងទឹកបានចំនួន២ដង នៅក្នុង ៧សាលាសហគមន៍ នៅក្នុងស្រុករុក្ខគិរី ។ | ការពិនិត្យពីគុណភាពការការងារសាងសង់ និងការបំពាក់សម្ភារៈ | | - | |

ថ្ងៃពុធ ៥កើត ខែ មិកសិរ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២

បាត់ដំបង, ថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០១៨

អ្នករៀបចំរបាយការណ៍

**សណ្តុះ មុនីភា**

បានឃើញ និង ឯកភាព

**ប្រធានអង្គភាព**

**ឃុន ម៉ុនលី**